# មគ្គុទ្ទេសក៍ណែនាំអំពី **មូលនិធិទឹកប្រាក់សំណង**

## តើអ្វីជា **មូលនិធិទឹកប្រាក់សំណងរបស់កម្មករ?**

កម្មករដែលធ្វើការឱ្យនិយោជក **កន្លែងលាងរថយន្ត** (CW), **រោងចក្រផលិតសម្លៀកបំពាក់** (GM) ឬ **ភ្នាក់ងារកម្មករកសិកម្ម (FLC)** ដែលមិនបង់ប្រាក់ឈ្នួល ឬចំនួនទឹកប្រាក់ត្រូវបង់ផ្សេងទៀត អាចទទួលបានមូលនិធិពីមូលនិធិទឹកប្រាក់សំណងកម្មករជាពិសេស ដែលបង្កើតឡើងសម្រាប់គោលបំណងផ្តល់ប្រភពឯករាជ្យ និងពិសេសនៃការស្តារឡើងវិញផ្នែកហិរញ្ញវត្ថុ។ មូលនិធិពិសេសទាំងនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ឱ្យកម្មករនូវមធ្យោបាយមួយដើម្បីទទួលបានទឹកប្រាក់ជំពាក់ ខណៈពេលការអនុវត្តនីតិវិធីកំពុងត្រូវបានអនុវត្តប្រឆាំងនឹងនិយោជកនៅក្នុងឧស្សាហកម្មទាំងនេះ។

មូលនិធិពិសេសទាំងនេះត្រូវបានចែងដោយច្បាប់ដូចខាងក្រោម៖

- **មូលនិធិពិសេសវិស័យកាត់ដេរ** (ក្រមការងារ §2675.5)
- **គណនីសំណងកម្មករកសិកម្ម** (ក្រមការងារ §1684(a)(4))
- **មូលនិធិទឹកប្រាក់សំណងកម្មករលាងរថយន្ត** (ក្រមការងារ §2065)

## តើនរណា
## **មានសិទ្ធិស្នើសុំមូលនិធិទឹកប្រាក់សំណង?**

កម្មករកាត់ដេរ កម្មករកសិដ្ឋាន ឬកម្មករលាងរថយន្ត ដែលមានសាលក្រមរបស់តុលាការ
ឬដីការដ្ឋបាលចុងក្រោយ
អាចធ្វើការស្នើសុំពីមូលនិធិទឹកប្រាក់សំណងដែលអាចអនុវត្តបាន។



កម្មករកាត់ដេរ
គឺជានិយោជិតដែលចូលរួមក្នុងដំណើរការសម្លៀកបំពាក់
ឬសម្ភារៈសម្លៀកបំពាក់
ឬគ្រឿងបន្ថែមណាមួយដែលត្រូវបានរចនា
ឬមានបំណងប្រើប្រាស់ដោយបុគ្គលណាម្នាក់សម្រាប់បុគ្គលម្នាក់ទៀត ដូចជា៖ ការដេរ ការកាត់ ការផលិត ការកែច្នៃ
ការជួសជុល ការរៀបចំដាយ ការផ្គុំ ការជ្រលក់ពណ៌
ការកែប្រែការរចនារបស់សម្លៀកបំពាក់
ការធ្វើឱ្យអ្នកបុគ្គលម្នាក់ទៀតកែប្រែរចនាសម្លៀកបំពាក់
ឬការបិទស្លាកលើសម្លៀកបំពាក់។ សម្លៀកបំពាក់រួមមាន
ប៉ុន្តែមិនកំណត់ដូចជា ខោអាវ មួក ស្រោមដៃ កាបូបដៃ
ស្រោមជើង ក្រវ៉ាត់ក កន្សែងបង់ក ឬខ្សែក្រវ៉ាត់។



បុគ្គលិកលាងរថយន្ត គឺជានិយោជិតដែលផ្តល់សេវាកម្មលាង
និងប៉ូលារថយន្តជាក់ស្តែង។



កម្មករកសិដ្ឋាន
គឺជានិយោជិតដែលផ្តល់សេវាកម្មទាក់ទងនឹងការដាំដុះ
ឬការផលិតផលិតផលកសិកម្មណាមួយ។

| មូលនិធិទឹកប្រាក់សំណង | មូលនិធិពិសេសវិស័យកាត់ដេរ (ក្រមការងារ §2675.5) | គណនីសំណងកម្មករកសិកម្ម (ក្រមការងារ 1684(a)(4)) | មូលនិធិសំណងទឹកប្រាក់កម្មករលាងរថយន្ត (ក្រមការងារ §2065) |
|---|---|---|---|
| កម្មករដែលមានសិទ្ធិសម្រាប់ | កម្មករកាត់ដេរ | កម្មករកសិកម្ម | កម្មករលាងរថយន្ត |
| ការងារជាមួយ | ឧស្សាហកម្មផលិតសម្លៀកបំពាក់ (GM) | ភ្នាក់ងារកម្មករកសិកម្ម (FLC) | ឧស្សាហកម្មលាងរថយន្ត (CW) |

## តើខ្ញុំគួរទាក់ទងអ្នកណា
**ដើម្បីធ្វើសំណើសុំមូលនិធិទឹកប្រាក់សំណងសម្រាប់ GM, FLC ឬ CW?**

អនុប្រធានដែលបានចាត់តាំងឱ្យទទួលបន្ទុកសំណុំរឿងរបស់អ្នកនឹងទាក់ទងអ្នកតាមប្រៃសណីយ៍ដើម្បីស្នើសុំឯកសារចាំបាច់ដើម្បីចាប់ផ្តើមដំណើរការ ឬអ្នកអាចទាក់ទងការិយាល័យរបស់មន្ត្រីទទួលបន្ទុកការងារក្នុងតំបន់ដើម្បីធ្វើសំណើ។ អ្នកនឹងឃើញព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យរបស់មន្ត្រីទទួលបន្ទុកការងារនៅទីនេះ៖

**https://www.dir.ca.gov/dlse/DistrictOffices.htm**

## តើកម្មករត្រូវការឯកសារអ្វីខ្លះ
**សម្រាប់ដំណើរការមូលនិធិទឹកប្រាក់សំណង?**

- ភស្តុតាងនៃអត្តសញ្ញាណ
- ភស្តុតាងនៃ SSN ឬលេខសម្គាល់អ្នកជាប់ពន្ធបុគ្គល (ITIN)
- បំពេញ និងចុះហត្ថលេខាលើកំណត់ត្រាទិន្នន័យអត្ថាគាហក (STD 204) និងឯកសារបន្ថែមកំណត់ត្រាទិន្នន័យអត្ថាគាហក (STD 205)

# តើមានអ្វីកើតឡើង

**បន្ទាប់ពីខ្ញុំដាក់ស្នើឯកសារដែលត្រូវការ/ស្នើសុំ?**

អនុប្រធានដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកសំណុំរឿងរបស់អ្នកនឹងដាក់ស្នើកញ្ចប់មូលនិធិទឹកប្រាក់សំណងរបស់អ្នកសម្រាប់ការផ្ទៀងផ្ទាត់។ បន្ទាប់ពីឯកសាររបស់អ្នកត្រូវបានផ្ទៀងផ្ទាត់រួច ហើយមូលនិធិទឹកប្រាក់សំណងអាចអាចអនុវត្តបានគឺនៅមាន ការិយាល័យរបស់អ្នកត្រួតពិនិត្យរដ្ឋនឹងចេញមូលប្បទានប័ត្រសម្រាប់ចំនួនទឹកប្រាក់ដែលមានសិទ្ធិទទួលបាន។ អនុប្រធាននឹងទាក់ទងអ្នកដើម្បីធ្វើការរៀបចំផ្តល់ថវិកា។ សូមចំណាំថា មូលនិធិត្រូវបានបំពេញឡើងវិញជារៀងរាល់ឆ្នាំ ហើយត្រូវបានផ្តល់ជូនតាមគោលការណ៍អ្នកណាមកមុនបានមុន។ ក្នុងករណីដែលថវិកាមិនគ្រប់គ្រាន់ ពេលវេលារង់ចាំអាចត្រូវបានពន្យារពេល។

# តើខ្ញុំត្រូវទទួលបាន ឬបន្តថ្មី

**លេខសម្គាល់អ្នកជាប់ពន្ធបុគ្គល (ITIN) ដោយរបៀបណា**

សំណើ ITIN តម្រូវឱ្យបំពេញ និងផ្ញើទម្រង់បែបបទ W-7 ជាមួយនឹងភស្តុតាងអត្តសញ្ញាណច្បាប់ដើម និងឯកសារស្ថានភាពជនបរទេសទៅកាន់ IRS ដោយផ្ទាល់។ អ្នកអាចទាក់ទង IRS ដោយផ្ទាល់តាមលេខ 800-829-1040 ឬចូលមើលគេហទំព័ររបស់ IRS សម្រាប់ព័ត៌មានលម្អិតអំពីដំណើរការដាក់ពាក្យស្នើសុំ ITIN ឬបន្តថ្មី

**https://www.irs.gov/individuals/how-do-i-apply-for-an-itin)**

IRS ក៏ផ្តល់ជូននូវសេវាកម្មដោយផ្ទាល់របស់ភ្នាក់ងារការទទួលយកការធ្វើការបញ្ជាក់ដែលមានការអនុញ្ញាតពី IRS ផងដែរ។ នេះនឹងរារាំងអ្នកពីការផ្ញើឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារស្ថានភាពជនបរទេសរបស់អ្នកតាមប្រៃសណីយ៍។